# ការធ្វើតេស្ត៖ ជំងឺរលាកថ្លើមប្រភេទ C

មធ្យោបាយតែមួយគត់ដើម្បីដឹង ថាតើមនុស្សម្នាក់មានជំងឺរលាកថ្លើមប្រភេទ C ឬអត់ គឺដោយការធ្វើតេស្តឈាម។

## 1.ការធ្វើតេស្តអង្គបដិបក្ខ

នេះនឹងបង្ហាញថាតើមនុស្សម្នាក់ធ្លាប់ដែលបានប៉ះពាល់នឹងវីរុសដែរឬអត់។ វាមិនមានន័យថាពួកគេបច្ចុប្បន្នមានជំងឺរលាកថ្លើមប្រភេទ C នោះទេ។ វាមានសារៈសំខាន់ណាស់ក្នុងការធ្វើតេស្តលើកទីពីរ ប្រសិនបើការធ្វើតេស្តអង្គបដិបក្ខនេះជាលទ្ធផលវិជ្ជមាន។

សំខាន់៖ វាជារឿងសំខាន់ដែលត្រូវដឹងថា ការធ្វើតេស្តអង្គបដិប្រាណវិជ្ជមាន មិនមានន័យថាអ្នកត្រូវបានការពារប្រឆាំងនឹង ឬមានភាពស៊ាំនឹងជំងឺរលាកថ្លើមប្រភេទ C នោះទេ។ មិនមានការចាក់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ C ទេ ហើយអ្នកអាចឆ្លងជំងឺរលាកថ្លើមប្រភេទ C ច្រើនជាងម្តង។

## 2.ការធ្វើតេស្តរកមើលមេរោគ (តេស្ត PCR)

តេស្ត PCR រកមើលមេរោគ ហើយត្រូវបានប្រើដើម្បីកំណត់ ថាតើបច្ចុប្បន្នមនុស្សម្នាក់មានជំងឺរលាកថ្លើមប្រភេទ C ឬអត់។

ការធ្វើតេស្តទាំងនេះជាធម្មតាត្រូវបានបញ្ជាទុក  និងអនុវត្តនៅថ្ងៃតែមួយ។ សេវាកម្មឯកទេសខាងឱសថ និងគ្រឿងញៀន គ្រឿងស្រវឹង មានបទពិសោធន៍យ៉ាងច្រើន ហើយអាចមានឧបករណ៍ដើម្បីស្វែងរកលទ្ធផលយ៉ាងត្រឹមត្រូវពីការធ្វើតេស្តឈាម។

## <u>FibroScan</u>

នេះគឺជាអេកូពិសេសដែលប៉ាន់ស្មានពីទំហំនៃការខូចថ្លើម។ ពេលខ្លះ FibroScan ត្រូវធ្វើមុនពេលទទួលការព្យាបាល ហើយវេជ្ជបណ្ឌិតរបស់អ្នក នឹងអាចផ្តល់ដំបូន្មានអំពីកន្លែងដែលត្រូវធ្វើ។
វាជាដំណើរការឆាប់រហ័ស ងាយស្រួល និងគ្មានការឈឺចាប់។

LiverWELL
Incorporating HEPATITIS VICTORIA

GILEAD

Supported by a grant from Gilead Sciences